# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## សម្រាប់ការិយបរិច្ឆេទ 6 ខែ ដែលបានបញ្ចប់
## ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019
## និង
## របាយការណ៍របស់សវនករឯករាជ្យ
## ស្តីពីការពិនិត្យព័ត៌មានហិរញ្ញវត្ថុចន្លោះពេល

# ព័ត៌មានអំពីក្រុមហ៊ុន

| | |
|---|---|
| ក្រុមហ៊ុន | **អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី** |
| ចុះបញ្ជីពាណិជ្ជកម្មលេខ | 00012829 |
| ទីស្នាក់ការ | អាគារលេខ 666B ផ្លូវលេខ 271 សង្កាត់ផ្សារដើមថ្កូវ<br>ខណ្ឌចំការមន រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា |
| ភាគទុនិក | LOLC Private Limited<br>TPC-ESOP CO., LTD. |
| ក្រុមប្រឹក្សាភិបាល | លោក Brindley Chrishantha Gajanayake de Zylva, ប្រធានក្រុមប្រឹក្សាភិបាល<br>លោក Indrajith Wijesiriwardana, សមាជិក<br>លោក Hans Michael Theodor Moormann, សមាជិក<br>លោក Dulip Rasika Samaraweera, សមាជិក<br>លោក Francisco Kankanamalage Conrad Prasad Nirosh Dias, សមាជិក |
| គណៈកម្មការសវនកម្ម | លោក Hans Michael Theodor Moormann, ប្រធាន<br>លោក Brindley Chrishantha Gajanayake de Zylva, សមាជិក<br>លោក Indrajith Wijesiriwardana, សមាជិក |
| គណៈកម្មការគ្រប់គ្រងហានិភ័យ | លោក Hans Michael Theodor Moormann, ប្រធាន<br>លោក Brindley Chrishantha Gajanayake de Zylva, សមាជិក<br>លោក Francisco Kankanamalage Conrad Prasad Nirosh Dias, សមាជិក |
| កម្មាធិការ គណៈកម្មធិការ តែងតាំង និង ផ្តល់តម្លៃការ | លោក Indrajith Wijesiriwardana, ប្រធាន<br>លោក Dulip Rasika Samaraweera, សមាជិក<br>លោក Francisco Kankanamalage Conrad Prasad Nirosh Dias, សមាជិក |

# ព័ត៌មានអំពីក្រុមហ៊ុន (ត)

| | | |
|---|---|---|
| គណៈគ្រប់គ្រង | លោក សុខ រឿន | ប្រធាននាយកប្រតិបត្តិ |
| | លោក សុខ សុផល | អនុប្រធាននាយកប្រតិបត្តិ/ប្រធាននាយកហិរញ្ញវត្ថុ |
| | លោក Damburae Liyanage Duleep Roshan | ប្រធាននាយកបច្ចេកវិទ្យាព័ត៌មាន |
| | លោក ទុន កង | នាយករងនាយកដ្ឋានឥណទាន |
| | អ្នកស្រី ឡេង ថាវី | នាយិកានាយកដ្ឋានធនធានមនុស្ស |
| | អ្នកស្រី ស៊ីយ សុឌីណា | នាយិកានាយកដ្ឋានហានិភ័យ |
| | អ្នកស្រី កែវ តារាទី | នាយិកានាយកដ្ឋានហិរញ្ញវត្ថុ |
| | អ្នកស្រី ទ្រី សូឡា | នាយិកានាយកដ្ឋានរតនាគារ |
| | អ្នកស្រី ឈាង កញ្ញា | ប្រធាននាយិកាឌីជីថលសេវាហិរញ្ញវត្ថុ និងប្រាក់បញ្ញើ |
| | លោក ហ៊ុល សុវត្ថា | នាយកនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន |
| | លោក សៀម ហាក់ | នាយកនាយកដ្ឋានរដ្ឋបាល និងធុរកិច្ច |
| | លោក ឈួន សុខចិត្ត | នាយកនាយកដ្ឋានទីផ្សារ |
| | លោក តេង ភាព | នាយកនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| | លោក បាន ផលឡេង | នាយកនាយកដ្ឋានអនុលោមភាព |
| | លោក នុត ថេង | នាយកនាយកដ្ឋានអាជីវកម្ម |
| | លោក មុត ពិសី | នាយកនាយកដ្ឋានឥណទាន |
| | លោក Romesh Perera | ប្រធាននាយកដ្ឋានបណ្តាញចែកចាយ |
| សវនករ | ខេភីអឹមជី ខេមបូឌា ចំកាត់ | |

## អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## មាតិកា

ទំព័រ


| | |
|---|---|
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | 1 |
| របាយការណ៍របស់សវនករឯករាជ្យស្តីពីការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុចន្លោះពេល | 7 |
| តារាងតុល្យការសង្ខេបចន្លោះពេល | 9 |
| របាយការណ៍លទ្ធផលសង្ខេបចន្លោះពេល | 11 |
| របាយការណ៍ស្តីពីបម្រែបម្រួលមូលធនសង្ខេបចន្លោះពេល | 13 |
| របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល | 14 |
| កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល | 16 |

អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី
LOLC (Cambodia) Plc.

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមធ្វើការបង្ហាញជូននូវរបាយការណ៍របស់ខ្លួន ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលដែលបានត្រួតពិនិត្យរួច របស់ក្រុមហ៊ុន **អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី** ហៅកាត់ថា (“ក្រុមហ៊ុន” ឬ “អិលអូអិលស៊ី”) សម្រាប់ការិយបរិច្ឆេទ 6 ខែ ដែលបានបញ្ចប់ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019 (ដែលតទៅនេះនឹងត្រូវហៅកាត់ថា “របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល”) ។

## អំពីក្រុមហ៊ុន

អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី (ត្រូវបានគេស្គាល់ថាជា ធនាគារភូមិ (ខេមបូឌា) អិលធីឌី) គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ ដែលបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ជាក្រុមហ៊ុនសាធារណៈទទួលខុសត្រូវមានកម្រិតក្រោមបញ្ជីការលេខ Co. 1413 E/2002 ចុះនៅថ្ងៃទី 23 ខែ ឧសភា ឆ្នាំ 2002 និងបានប្ដូរលេខចុះបញ្ជីទៅលេខ 00012829 នៅថ្ងៃទី 28 ខែ កញ្ញា ឆ្នាំ 2015 ។ បន្ទាប់ពីមានការផ្លាស់ប្ដូរម្ចាស់ភាគហ៊ុននៅខែ កញ្ញា ឆ្នាំ 2014 ក្រុមហ៊ុនបានក្លាយជាទៅក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ LOLC Micro Investments Ltd. ដែលជាក្រុមហ៊ុនត្រូវបានបង្កើតឡើងនៅប្រទេសស្រីលង្កា ។ ក្រុមហ៊ុនមេធំបំផុត គឺក្រុមហ៊ុន Lanka ORIX Leasing Company PLC ដែលជាក្រុមហ៊ុនមួយត្រូវបានបង្កើតឡើងនៅ ប្រទេសស្រីលង្កា និងត្រូវបានចុះបញ្ជីនៅក្នុងផ្សារហ៊ុន Colombo Stock Exchange ។

នៅថ្ងៃទី 16 ខែ កញ្ញា ឆ្នាំ 2017 LOLC Micro Investments Ltd និង DWM Investment Asia Ltd បានផ្ទេរ/លក់ភាគហ៊ុនរបស់ខ្លួនទាំងអស់ចំនួន 96.97 % ទៅឲ្យ LOLC Private Limited ។ នេះត្រូវបានអនុម័តដោយ ធនាគារជាតិនៃ កម្ពុជា នៅថ្ងៃទី 28 ខែ វិច្ឆិកា ឆ្នាំ 2017 ។ លើសពីនេះទៀតភាគហ៊ុនដែលត្រូវលក់ ត្រូវបានអនុម័តសម្រាប់ការផ្លាស់ប្ដូរកម្មសិទ្ធិដោយ ធនាគារជាតិ នៃកម្ពុជា នៅថ្ងៃទី 14 ខែ មីនា ឆ្នាំ 2018 និងត្រូវបានអនុម័តដោយក្រសួងពាណិជ្ជកម្មនៅថ្ងៃទី 25 ខែ មិថុនា ឆ្នាំ 2018 ។

នៅថ្ងៃទី 11 ខែ កញ្ញា ឆ្នាំ 2015 ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើស្ថាប័នមីក្រូហិរញ្ញវត្ថុ ដើម្បីធ្វើអាជីវកម្មទទួលប្រាក់បញ្ញើពី ធនាគារជាតិ នៃ កម្ពុជា ។

ក្រុមហ៊ុនមានទីតាំងការិយាល័យចំនួន 79 កន្លែង (78 សាខា និងការិយាល័យកណ្ដាលនៅរាជធានីភ្នំពេញ) ។ ទីស្នាក់ការចុះបញ្ជីក្រុមហ៊ុនស្ថិតនៅអគារលេខ 666 ផ្លូវ 271 សង្កាត់បឹងទំពុន 2 ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។



ការិយាល័យកណ្ដាល
អគារលេខ ៦៦៦យ ផ្លូវលេខ២៧១ ភូមិត្នោតជ្រុំ១ សង្កាត់បឹងទំពុន២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទលេខ៖ (+៨៥៥) ២៣ ៩៩១ ៩៩១ | អ៊ីម៉ែល៖ info@lolc.com.kh
គេហទំព័រ៖ www.lolc.com.kh | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | គ្រឹះស្ថានឯកជន

គំនិតរីកបំព្រើន

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុ (ទទួលប្រាក់បញ្ញើ និងផ្តល់ឥណទាន) ដល់ប្រជាជនកម្ពុជានៅតាមជនបទ និងសហគ្រាសខ្នាតតូចតាមរយៈទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ និងសាខានានានៅតាមបណ្តាខេត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ គោលបំណងសាជីវកម្មរបស់ក្រុមហ៊ុន គឺផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុ ដែលអាចទុកចិត្តបាននិងមានតម្លៃសមរម្យដល់សហគ្រាសខ្នាតតូច និងសហគ្រាសធុនតូច និងមធ្យម ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុចន្លោះពេលរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទ 6 ខែ ដែលបានបញ្ចប់ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019 ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនៅទំព័រទី 11 ដល់ទី 12 ។

## ភាគលាភ

ពុំមានការប្រកាស ឬការបែងចែកភាគលាភ ហើយក្រុមប្រឹក្សាភិបាលក៏ពុំមានអនុសាសន៍ឲ្យមានការបែងចែកភាគលាភ សម្រាប់ការិយបរិច្ឆេទនេះទេ ។

## ដើមទុន

នៅថ្ងៃទី 10 ខែ វិច្ឆិកា ឆ្នាំ 2018 ក្រុមហ៊ុនបានផ្ញើសំណើទៅធនាគារជាតិនៃកម្ពុជាដើម្បីបង្កើនដើមទុនពី 120,000,000 ពាន់រៀល (ស្មើនឹង 29,865,605 ដុល្លារអាមេរិក) ដល់ 140,846,600 ពាន់រៀល (ស្មើនឹង 34,640,089 ដុល្លារអាមេរិក) ។ សំណើនេះត្រូវបានអនុម័តដោយធនាគារជាតិ នៃ កម្ពុជា នៅថ្ងៃទី 22 ខែ កុម្ភៈ ឆ្នាំ 2019 ។

## ដើមទុនបន្ថែម

នៅថ្ងៃទី 3 ខែ មិថុនា ឆ្នាំ 2019 ក្រុមប្រឹក្សាភិបាលបានអនុម័តបង្កើនដើមទុនទៅចំនួន 182,612,000 ពាន់រៀលដោយការដាក់បញ្ចូលដើមទុនជាសាច់ប្រាក់សុទ្ធពី LOLC Private Limited ចំនួន 40,500,000 ពាន់រៀល និង TPC-ESOP Co., Ltd. ចំនួន 1,265,400 ពាន់រៀល ។ នាថ្ងៃចេញរបាយការណ៍នេះ ក្រុមហ៊ុនបានទទួលដើមទុនជាសាច់ប្រាក់សុទ្ធពី LOLC Private Limited ចំនួន 20,375,000 ពាន់រៀល និង TPC-ESOP Co., Ltd. ចំនួន 1,265,400 ពាន់រៀល ។ នៅថ្ងៃទី 8 ខែ កក្កដា ឆ្នាំ 2019 ក្រុមហ៊ុន បានទទួលដើមទុនជាសាច់ប្រាក់ដែលនៅសល់ចំនួន 20,375,000 ពាន់រៀល ពី LOLC Private Limited ។ នាថ្ងៃចេញរបាយការណ៍នេះ ក្រុមហ៊ុនកំពុងរង់ចាំការអនុម័តពីធនាគារជាតិនៃកម្ពុជា និងការយល់ព្រមពីក្រសួងពាណិជ្ជកម្ម សម្រាប់ការកែប្រែ លក្ខន្តិកៈក្រុមហ៊ុនថ្មីនេះ ។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តលើទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ ។


ការិយាល័យកណ្តាល
អគារលេខ ៦៦៦ខ ផ្លូវលេខ២៧១ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ៖ (+៨៥៥) ២៣ ៩៩១ ៩៩១ | អ៊ីម៉ែល៖ info@lolc.com.kh
គេហទំព័រ៖ www.lolc.com.kh | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | គ្រឹះស្ថានឯកជន

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## ឥណទានអាក្រក់ និងឥណទានជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្រប ដើម្បីបញ្ជាក់ថាវិធានការទាក់ទងទៅនឹងការលុបចោលឥណទានអាក្រក់ និងការធ្វើសំវិធានធន លើឥណទានជាប់សង្ស័យ ត្រូវបានធ្វើឡើងដោយអ្នកគ្រប់គ្រង ឬក្រុមហ៊ុន ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថា រាល់ឥណទានដែលបានដឹងថាមិនអាចទារបាន ត្រូវបានលុបចោល ហើយសំវិធានធនត្រូវបានធ្វើឡើងយ៉ាងគ្រប់គ្រាន់សម្រាប់ឥណទានដែលអាក្រក់ និងជាប់សង្ស័យ ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយដែលនាំឲ្យឥណទានអាក្រក់ដែលបានលុបចេញពីបញ្ជី ឬចំនួនសំវិធានធនជាប់សង្ស័យក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុនមានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះទេ ។

## ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានធានាថា អ្នកគ្រប់គ្រង ឬក្រុមហ៊ុនបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា បណ្តាទ្រព្យសកម្មចរន្តទាំងអស់ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ហើយដែលទំនងជាមិនអាចទទួលស្គាល់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានកាត់បន្ថយឲ្យស្មើនឹងតម្លៃដែលគិតថានឹងអាចប្រមូលបានជាក់ស្តែង ។

## វិធីសាស្ត្រកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង ដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវ និងមិនសមស្របនោះទេ ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗ

នាថ្ងៃចេញរបាយការណ៍នេះ គឺពុំមាន៖

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលកើតមានឡើងចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទ ក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាមួយឡើយ និង

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមកក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន ។

ក្រុមប្រឹក្សាភិបាល មានមតិថាពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗ ទៀតរបស់ក្រុមហ៊ុនដែលនឹងត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងរយៈពេល 12 ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ដែលនឹងធ្វើឲ្យមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់ ។



ការិយាល័យកណ្តាល
អគារលេខ ៦៦៦ឃ ផ្លូវលេខ២៧១ ភូមិក្បាលទំនប់១ សង្កាត់បឹងទំពុនទី២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ៖ (+៨៥៥) ២៣ ៩៩១ ៩៩១ | អ៊ីម៉ែល៖ info@lolc.com.kh
គេហទំព័រ៖ www.lolc.com.kh | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | គ្រឹះស្ថានឯកជន

គំនិតរីកចម្រើន

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## ការផ្លាស់ប្តូរនៃហេតុការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនបានកែតម្រូវ នៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ដែលនឹងបណ្តាលឲ្យមានតួលេខនៃចំនួនណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលមានភាពមិនត្រឹមត្រូវនោះទេ ។

## ប្រការមិនប្រក្រតី

ក្រុមប្រឹក្សាភិបាលមានមតិថា លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើង ដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលបានបម្រើការក្នុងអំឡុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះរួមមាន៖

- លោក Brindley Chrishantha Gajanayake de Zylva — ប្រធានក្រុមប្រឹក្សាភិបាល
- លោក Indrajith Wijesiriwardana — សមាជិក
- លោក Hans Michael Theodor Moormann — សមាជិក
- លោក Dulip Rasika Samaraweera — សមាជិក
- លោក Francisco Kankanamalage Conrad Prasad Nirosh Dias — សមាជិក

## គណៈកម្មការសវនកម្ម

សមាជិកគណៈកម្មការសវនកម្ម ដែលបានបម្រើការក្នុងអំឡុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះរួមមាន៖

- លោក Hans Michael Theodor Moormann — ប្រធាន
- លោក Brindley Chrishantha Gajanayake de Zylva — សមាជិក
- លោក Indrajith Wijesiriwardana — សមាជិក

## គណៈកម្មការគ្រប់គ្រងហានិភ័យ

សមាជិក គណៈកម្មការគ្រប់គ្រងហានិភ័យ ដែលបានបម្រើការក្នុងអំឡុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍ នេះរួមមាន៖

- លោក Hans Michael Theodor Moormann — ប្រធាន
- លោក Brindley Chrishantha Gajanayake de Zylva — សមាជិក
- លោក Francisco Kankanamalage Conrad Prasad Nirosh Dias — សមាជិក



ការិយាល័យកណ្តាល
អគារលេខ ៦៦០យ ផ្លូវលេខ២៧១ ភូមិក្បាលទំនប់១ សង្កាត់បឹងទំពុនទី២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ៖ (+៨៥៥) ២៣ ៩៩១ ៩៩១ | អ៊ីម៉ែល៖ info@lolc.com.kh
គេហទំព័រ៖ www.lolc.com.kh | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | គ្រឹះស្ថានឯកជន

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## គណៈកម្មការតែងតាំង និងកំណត់លាភការ

សមាជិក គណៈកម្មការតែងតាំង និងកំណត់លាភការដែលបានបម្រើការក្នុងអំឡុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះ រួមមាន៖

| | |
|---|---|
| • លោក Indrajith Wijesiriwardana | ប្រធាន |
| • លោក Dulip Rasika Samaraweera | សមាជិក |
| • លោក Francisco Kankanamalage Conrad Prasad Nirosh Dias | សមាជិក |

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលបានរៀបចំឡើងយ៉ាងត្រឹមត្រូវ គ្រប់ទិដ្ឋិភាពជាសារវន្តទាំងអស់ ដោយអនុលោមទៅតាមគោលនយោបាយគណនេយ្យដែលត្រូវបានទទួលស្គាល់ និងប្រើប្រាស់ជាទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ ក្រុមប្រឹក្សាភិបាលធានាថាក្រុមហ៊ុន៖

(i) អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព ។

(ii) គោរពតាមគោលការណ៍គណនេយ្យដែលត្រូវបានទទួលស្គាល់ និងប្រើប្រាស់ជាទូទៅ នៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ការរាយការណ៍ចន្លោះពេល ឬប្រសិនបើមានការខុសប្លែកពីនេះ ដើម្បីបង្ហាញភាពពិត និងត្រឹមត្រូវ គឺត្រូវតែបង្ហាញ និងពន្យល់ឲ្យបានច្បាស់លាស់ និងកំណត់បរិមាណនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ។

(iii) ត្រួតពិនិត្យប្រព័ន្ធដំណើរការរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន និងរក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព ។

(iv) វាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មានប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជីផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ ។

(v) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឲ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេច ដែលមានសារៈសំខាន់ទាំងអស់ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ។

ក្រុមប្រឹក្សាភិបាលសូមធានាអះអាងថា បានបំពេញ និងអនុវត្តនូវរាល់ការទទួលខុសត្រូវដូចមានរាយការណ៍ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ ។


ការិយាល័យកណ្តាល
អគារលេខ ៦៦៦ខ ផ្លូវលេខ២៧១ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ៖ (+៨៥៥) ២៣ ៩៩១ ៩៩១ | អ៊ីម៉ែល៖ info@lolc.com.kh
គេហទំព័រ៖ www.lolc.com.kh | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | គ្រឹះស្ថានឯកជន

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

យើងខ្ញុំ តំណាងឲ្យក្រុមប្រឹក្សាភិបាលសូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដែលភ្ជាប់មកជាមួយ ដូចបានបង្ហាញនៅទំព័រទី ๑ ដល់ទី 42 ថាត្រូវបានរៀបចំឡើង គ្រប់ទិដ្ឋិភាពជាសារវន្តទាំងអស់ ដោយអនុលោមទៅតាមគោលនយោបាយគណនេយ្យដែលត្រូវបានទទួលស្គាល់ និងប្រើប្រាស់ជាទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល ។

*ចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាល៖*

លោក សុខ វឿន
*ប្រធាននាយកប្រតិបត្តិ*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី: 14 AUG 2019



ការិយាល័យកណ្តាល
អគារលេខ ៦៦៦៨ ផ្លូវលេខ២៧១ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទលេខ៖ (+៨៥៥) ២៣ ៩៩១ ៩៩១ | អ៊ីម៉ែល៖ info@lolc.com.kh
គេហទំព័រ៖ www.lolc.com.kh | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | គ្រឹះស្ថានឯកជន

គាំទ្រការរីកចម្រើន

KPMG

KPMG Cambodia Ltd
4th Floor, Delano Center
No. 144, Street 169, Sangkat Veal Vong
Khan 7 Makara, Phnom Penh
Kingdom of Cambodia
+855 23 216 899 | kpmg.com.kh

# របាយការណ៍របស់សវនករឯករាជ្យស្តីពីការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុចន្លោះពេល

## ជូនចំពោះភាគទុនិក
## អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

### *សេចក្តីផ្តើម*

យើងខ្ញុំ បានធ្វើការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល របស់ក្រុមហ៊ុន **អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី** ហៅកាត់ថា (“ក្រុមហ៊ុន” ឬ “អិលអូអិលស៊ី”) ដែលរួមមានតារាងតុល្យការសង្ខេបចន្លោះពេល នាថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019 របាយការណ៍លទ្ធផលសង្ខេបចន្លោះពេល និងរបាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងលំហូរទឹកប្រាក់សង្ខេបចន្លោះពេល សម្រាប់ការិយបរិច្ឆេទ 6 ខែ ដែលបានបញ្ចប់ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019 និងកំណត់សំគាល់ផ្សេងៗទៀតដែលបានបង្ហាញនៅទំព័រទី 9 ដល់ទី 42 ហៅកាត់ថា (“របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល”) ។

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយអនុលោមតាមគោលនយោបាយគណនេយ្យដែលត្រូវបានទទួលស្គាល់ និងប្រើប្រាស់ជាទូទៅ នៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល ។ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺផ្តល់ការសន្និដ្ឋានលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលដោយផ្អែកលើការធ្វើការត្រួតពិនិត្យរបស់យើងខ្ញុំ ។

### *ទំហំនៃការត្រួតពិនិត្យ*

យើងខ្ញុំ បានធ្វើការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិនៃកម្ពុជាសម្រាប់ កិច្ចព្រមព្រៀងត្រួតពិនិត្យ លេខ 2410 “ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុចន្លោះពេល ដែលអនុវត្តដោយសវនករឯករាជ្យរបស់ក្រុមហ៊ុន” ។ ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល រួមមានការសាកសួរព័ត៌មាន ជាពិសេសសាកសួរបុគ្គលដែលមានភារៈទទួលខុសត្រូវលើបញ្ហាគណនេយ្យ និងហិរញ្ញវត្ថុ និងធ្វើការវិភាគ និងនីតិវិធីត្រួតពិនិត្យផ្សេងៗ ។ ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុចន្លោះពេលមានទំហំតូចជាងការធ្វើសវនកម្មដែលអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ហេតុដូច្នេះ វាមិនអាចឲ្យយើងខ្ញុំ ផ្តល់នូវអំណះអំណាងថា យើងខ្ញុំបានស្វែងយល់អំពីបញ្ហាជាសារវន្តទាំងអស់ ដែលអាចនឹងត្រូវបានរកឃើញក្នុងពេលធ្វើសវនកម្មបានឡើយ ។ ហេតុដូច្នេះយើងខ្ញុំ មិនបញ្ចេញមតិសវនកម្មនោះទេ ។

KPMG Cambodia Ltd, a Cambodian limited liability company and a member firm of the KPMG network of independent member firms affiliated with KPMG International Cooperative ("KPMG International"), a Swiss entity.
Document classification: KPMG Confidential

*ការសន្និដ្ឋាន*

ផ្អែកលើការត្រួតពិនិត្យរបស់យើងខ្ញុំ ពុំមានបញ្ហាណាមួយទាញចំណាប់អារម្មណ៍យើងខ្ញុំ ដែលបណ្តាលឲ្យយើងខ្ញុំជឿថា របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលសម្រាប់រយៈពេល 6 ខែ ដែលបញ្ចប់ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019 មិនត្រូវបានរៀបចំ គ្រប់ទិដ្ឋិភាពជាសារវន្ត ស្របតាមតាមគោលនយោបាយគណនេយ្យដែលត្រូវបានទទួលស្គាល់ និងប្រើប្រាស់ជាទូទៅ នៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់របាយការណ៍ហិរញ្ញវត្ថុចន្លោះពេលនោះទេ ។

*បញ្ហាផ្សេងៗ*

យើងខ្ញុំសូមទាញចំណាប់អារម្មណ៍ថា យើងខ្ញុំពុំបានត្រួតពិនិត្យ របាយការណ៍លទ្ធផលសង្ខេបចន្លោះពេល និងរបាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងលំហូរទឹកប្រាក់សង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទ 3 ខែ ដែលបានបញ្ចប់នៅថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019 និងឆ្នាំ 2018 និងការិយបរិច្ឆេទ 6 ខែ ដែលបានបញ្ចប់ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2018 ឬកំណត់សំគាល់ណាមួយដែលពាក់ព័ន្ធ ហេតុដូច្នេះយើងខ្ញុំមិនបានបញ្ចេញការសន្និដ្ឋាន ឬផ្តល់នូវអំណះអំណាងណាមួយទៅលើរបាយការណ៍ទាំងនោះឡើយ ។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា ចំកាត់**

Lim Chew Teng
*Partner*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី 14 ខែ សីហា ឆ្នាំ 2019

# អេលអូអេលស៊ី (ខេមបូឌា) ភីអិលស៊ី

## តារាងតុល្យការសង្ខេបចន្លោះពេល
## នាថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019

| | កំណត់សំគាល់ | នាថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019 ពាន់រៀល | នាថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019 ដុល្លារអាមេរិក (កំណត់សំគាល់ 4) | នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 ពាន់រៀល | នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 ដុល្លារអាមេរិក (កំណត់សំគាល់ 4) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | | 42,811,561 | 10,529,159 | 49,019,393 | 12,199,948 |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | | 537,659,614 | 132,233,059 | 317,522,406 | 79,024,989 |
| សមតុល្យនៅធនាគារនានា | 6 | 116,863,113 | 28,741,542 | 108,150,865 | 26,916,591 |
| ឥណទានផ្តល់ដល់អតិថិជន - សុទ្ធ | 7 | 2,499,661,555 | 614,771,656 | 1,928,675,767 | 480,008,902 |
| ទ្រព្យសកម្មផ្សេងៗ | | 47,457,423 | 11,671,772 | 44,105,879 | 10,977,073 |
| ការវិនិយោគ | | 60,990 | 15,000 | 60,270 | 15,000 |
| ទ្រព្យ និងបរិក្ខារ | 8 | 8,730,628 | 2,147,228 | 6,544,540 | 1,628,806 |
| ទ្រព្យសកម្មអរូបី | 9 | 4,572,008 | 1,124,449 | 4,505,809 | 1,121,406 |
| ពន្ធពន្យារជាទ្រព្យសកម្ម - សុទ្ធ | 10 | 9,207,922 | 2,264,614 | 7,581,894 | 1,886,982 |
| **សរុបទ្រព្យសកម្ម** | | 3,267,024,814 | 803,498,479 | 2,466,166,823 | 613,779,697 |
| **បំណុលនិងមូលធន** | | | | | |
| **បំណុល** | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារ និង ស្ថាប័នហិរញ្ញវត្ថុនានា | 11 | 99,322,554 | 24,427,583 | 76,466,224 | 19,030,917 |
| ប្រាក់បញ្ញើរបស់អតិថិជន | 12 | 1,312,873,692 | 322,890,726 | 858,618,040 | 213,692,892 |
| សំវិធានធនលើអត្ថប្រយោជន៍ របស់និយោជិត | 13 | 2,657,036 | 653,477 | 4,323,740 | 1,076,093 |
| បំណុលផ្សេងៗ | | 64,550,342 | 15,875,638 | 64,295,429 | 16,001,848 |
| ប្រាក់កម្ចី | 14 | 1,250,743,953 | 307,610,416 | 1,088,456,511 | 270,895,100 |
| មូលបត្របំណុល | 15 | 80,411,797 | 19,776,635 | - | - |
| បំណុលពន្ធលើប្រាក់ចំណេញ ប្រចាំឆ្នាំ | 21(ក) | 15,279,489 | 3,757,867 | 20,523,933 | 5,107,997 |
| **សរុបបំណុល** | | 2,825,838,863 | 694,992,342 | 2,112,683,877 | 525,804,847 |

# អេលអូអេលស៊ី (ខេមបូឌា) ភីអិលស៊ី

## តារាងតុល្យការសង្ខេបចន្លោះពេល (ត)
## នាថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019

| | | នាថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019 | | នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 | |
|---|---|---|---|---|---|
| | កំណត់សំគាល់ | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សំគាល់ 4) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សំគាល់ 4) |
| **មូលធន** | | | | | |
| ដើមទុន | 16 | 140,846,600 | 34,640,089 | 120,000,000 | 29,865,605 |
| ទុនបម្រុង | | 110,415,116 | 27,155,710 | 110,415,116 | 27,480,118 |
| ដើមទុនបន្ថែម | 17 | 21,640,400 | 5,322,282 | 20,846,600 | 5,188,303 |
| ប្រាក់ចំណេញរក្សាទុក | | 168,283,835 | 41,388,056 | 102,221,230 | 25,440,824 |
| **សរុបមូលធន** | | 441,185,951 | 108,506,137 | 353,482,946 | 87,974,850 |
| **សរុបបំណុល និងមូលធន** | | 3,267,024,814 | 803,498,479 | 2,466,166,823 | 613,779,697 |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ ។

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## របាយការណ៍លទ្ធផលសង្ខេបចន្លោះពេល
## សម្រាប់ការិយបរិច្ឆេទ 6 ខែ ដែលបានបញ្ចប់ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019

| | | សម្រាប់ការិយបរិច្ឆេទ 3 ខែ ដែលបានបញ្ចប់ | | | | សម្រាប់ការិយបរិច្ឆេទ 6 ខែ ដែលបានបញ្ចប់ | | | |
|---|---|---|---|---|---|---|---|---|---|
| | | ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019 (មិនបានត្រួតពិនិត្យ) | | ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2018 (មិនបានត្រួតពិនិត្យ) | | ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019 | | ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2018 (មិនបានត្រួតពិនិត្យ) | |
| | កំណត់សំគាល់ | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សំគាល់ 4) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សំគាល់ 4) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សំគាល់ 4) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សំគាល់ 4) |
| ចំណូលពីការប្រាក់ | 18 | 103,290,262 | 25,403,409 | 71,038,006 | 17,484,127 | 193,334,358 | 47,549,030 | 136,421,121 | 33,576,451 |
| ចំណាយលើការប្រាក់ | 18 | (49,020,900) | (12,056,296) | (29,408,511) | (7,238,127) | (90,013,967) | (22,138,211) | (54,604,311) | (13,439,407) |
| **ចំណូលពីការប្រាក់សុទ្ធ** | 18 | 54,269,362 | 13,347,113 | 41,629,495 | 10,246,000 | 103,320,391 | 25,410,819 | 81,816,810 | 20,137,044 |
| ចំណូលផ្សេងៗ | 19 | 29,585,140 | 7,276,227 | 16,928,106 | 4,166,406 | 58,745,521 | 14,447,988 | 34,614,191 | 8,519,368 |
| ចំណាយកម្រៃជើងសារ | | (904,285) | (222,402) | (610,388) | (150,231) | (1,788,801) | (439,941) | (1,163,947) | (286,475) |
| ចំណាយលើបុគ្គលិក | 20 | (23,971,200) | (5,895,524) | (18,168,561) | (4,471,711) | (45,304,845) | (11,142,362) | (35,190,720) | (8,661,265) |
| រំលស់លើទ្រព្យ និងបរិក្ខារ | 8 | (1,093,023) | (268,820) | (960,603) | (236,427) | (2,050,355) | (504,268) | (1,937,831) | (476,946) |
| រំលស់លើទ្រព្យសកម្មអរូបី | 9 | (87,394) | (21,494) | (47,757) | (11,754) | (172,377) | (42,395) | (94,989) | (23,379) |
| ចំណាយទូទៅ និងរដ្ឋបាល | | (11,393,277) | (2,802,084) | (9,025,123) | (2,221,295) | (21,175,587) | (5,207,966) | (17,194,986) | (4,232,090) |
| ចំណេញ/(ខាត) ពីការប្តូររូបិយប័ណ្ណបរទេស | | 948,276 | 233,221 | (214,012) | (52,673) | 895,390 | 220,214 | 123,584 | 30,417 |

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## របាយការណ៍លទ្ធផលសង្ខេបចន្លោះពេល (ត)
## សម្រាប់ការិយបរិច្ឆេទ 6 ខែ ដែលបានបញ្ចប់ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019

| | | សម្រាប់ការិយបរិច្ឆេទ 3 ខែ ដែលបានបញ្ចប់ | | | | សម្រាប់ការិយបរិច្ឆេទ 6 ខែ ដែលបានបញ្ចប់ | | | |
|---|---|---|---|---|---|---|---|---|---|
| | | ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019 (មិនបានត្រួតពិនិត្យ) | | ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2018 (មិនបានត្រួតពិនិត្យ) | | ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019 | | ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2018 (មិនបានត្រួតពិនិត្យ) | |
| | កំណត់សំគាល់ | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សំគាល់ 4) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សំគាល់ 4) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សំគាល់ 4) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សំគាល់ 4) |
| **ចំណេញពីប្រតិបត្តិការ** | | 47,353,599 | 11,646,237 | 29,531,157 | 7,268,315 | 92,469,337 | 22,742,089 | 60,972,112 | 15,006,674 |
| សំវិធានធនលើឧបករណ៍ហិរញ្ញវត្ថុ អាក្រក់និងជាប់សង្ស័យ | 7(ក) | (4,631,509) | (1,139,082) | (3,480,401) | (856,609) | (9,526,759) | (2,343,030) | (8,487,139) | (2,088,885) |
| **ប្រាក់ចំណេញមុនដកពន្ធ** | | 42,722,090 | 10,507,154 | 26,050,756 | 6,411,706 | 82,942,578 | 20,399,059 | 52,484,973 | 12,917,789 |
| ចំណាយពន្ធលើប្រាក់ចំណេញ | 21(ខ) | (8,750,326) | (2,152,072) | (5,296,149) | (1,303,507) | (16,879,973) | (4,151,494) | (10,704,918) | (2,634,733) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | 33,971,764 | 8,355,083 | 20,754,607 | 5,108,199 | 66,062,605 | 16,247,565 | 41,780,055 | 10,283,056 |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ ។

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## របាយការណ៍ស្តីពីបម្រែបម្រួលមូលធនសង្ខេបចន្លោះពេល
## សម្រាប់ការិយបរិច្ឆេទ 6 ខែ ដែលបានបញ្ចប់ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019

| | ដើមទុន<br>ពាន់រៀល | ទុនបម្រុង<br>ពាន់រៀល | ដើមទុនបន្ថែម<br>ពាន់រៀល | ប្រាក់ចំណេញរក្សាទុក<br>ពាន់រៀល | សរុប<br>ពាន់រៀល |
|---|---|---|---|---|---|
| **សម្រាប់ការិយបរិច្ឆេទ 6 ខែដែលបានបញ្ចប់ ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2018** | | | | | |
| នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 | 71,684,100 | 71,684,410 | - | 172,753,435 | 251,605,945 |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅជាដើមទុន | 48,315,900 | - | - | (48,315,900) | - |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | 41,780,055 | 41,780,055 |
| នាថ្ងៃទី30 ខែ មិថុនា ឆ្នាំ 2018 (មិនបានត្រួតពិនិត្យ) | 120,000,000 | 7,168,410 | - | 166,217,590 | 293,386,000 |
| (សមមូលជាដុល្លារអាមេរិក - កំណត់សំគាល់ 4) (មិនបានត្រួតពិនិត្យ) | 29,534,826 | 1,764,315 | - | 40,910,064 | 72,209,205 |
| **សម្រាប់ការិយបរិច្ឆេទ 6 ខែ ដែលបានបញ្ចប់ ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019** | | | | | |
| នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2019 | 120,000,000 | 110,415,116 | 20,846,600 | 102,221,230 | 353,482,946 |
| ការផ្ទេរពីដើមទុនបន្ថែមទៅជាដើមទុន | 20,846,600 | - | (20,846,600) | - | - |
| ដើមទុនបន្ថែម | - | - | 21,640,400 | - | 21,640,400 |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | 66,062,605 | 66,062,605 |
| នាថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019 | 140,846,600 | 110,415,116 | 21,640,400 | 168,283,835 | 441,185,951 |
| (សមមូលជាដុល្លារអាមេរិក - (កំណត់សំគាល់ 4) | 34,640,089 | 27,155,710 | 5,322,282 | 41,388,056 | 108,506,137 |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ ។

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល
## សម្រាប់ការិយបរិច្ឆេទ 6 ខែ ដែលបានបញ្ចប់ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019

| | កំណត់សំគាល់ | សម្រាប់ការិយបរិច្ឆេទ 6 ខែ ដែលបញ្ចប់ ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019 ពាន់រៀល | ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019 ដុល្លារអាមេរិក (កំណត់សំគាល់ 4) | ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2018 (មិនបានត្រួតពិនិត្យ) ពាន់រៀល | ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2018 (មិនបានត្រួតពិនិត្យ) ដុល្លារអាមេរិក (កំណត់សំគាល់ 4) |
|---|---|---|---|---|---|
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ប្រាក់ចំណេញមុនដកពន្ធ | | 82,942,578 | 20,399,059 | 52,484,973 | 12,917,789 |
| *និយ័តភាពលើ:* | | | | | |
| រំលស់លើទ្រព្យ និងបរិក្ខារ | 8 | 2,050,355 | 504,268 | 1,937,831 | 476,946 |
| រំលស់លើទ្រព្យសកម្មអរូបី | 9 | 172,377 | 42,395 | 94,989 | 23,379 |
| សំវិធានធនលើឥណទាន អាក្រក់ និងជាប់សង្ស័យ | 7 | 9,438,757 | 2,321,387 | 8,487,139 | 2,088,885 |
| សំវិធានធនលើប្រាក់តម្កល់នៅ ធនាគារនានា | 7 | 88,002 | 21,643 | - | - |
| សំវិធានធនលើអត្ថប្រយោជន៍របស់ បុគ្គលិក | | (1,666,704) | (409,912) | - | - |
| ចំណេញពីការលក់ និងការលុប ចោលទ្រព្យ និងបរិក្ខារ | | (11,187) | (2,751) | (118,358) | (29,131) |
| ចំណូលពីការប្រាក់សុទ្ធ | | (103,320,391) | (25,410,819) | (81,816,810) | (20,137,044) |
| | | (10,306,213) | (2,534,730) | (18,930,236) | (4,659,176) |
| បម្រែបម្រួលនៃ: | | | | | |
| ប្រាក់បម្រុងកាតព្វកិច្ចតម្កល់នៅ ធនាគារជាតិនៃកម្ពុជា | | (37,663,429) | (9,263,017) | (19,224,265) | (4,731,544) |
| សមតុល្យនៅធនាគារនានា | | - | - | (31,200) | (7,679) |
| ឥណទានផ្តល់ដល់អតិថិជន | | (580,423,685) | (142,750,537) | (337,510,695) | (83,069,332) |
| គណនីត្រូវទទួលផ្សេងៗ | | 700,453 | 172,271 | (4,695,057) | (1,155,564) |
| ប្រាក់បញ្ញើរបស់ធនាគារនិងស្ថាប័ន ហិរញ្ញវត្ថុនានា | | 22,856,330 | 5,621,331 | 14,022,042 | 3,451,155 |
| ប្រាក់បញ្ញើរបស់អតិថិជន | | 454,255,652 | 111,720,524 | 167,176,464 | 41,146,065 |
| បំណុលផ្សេងៗ | | (10,389,922) | (2,555,318) | 1,704,852 | 419,604 |
| **សាច់ប្រាក់ប្រើក្នុងប្រតិបត្តិការ** | | (160,970,814) | (39,589,476) | (197,488,095) | (48,606,471) |
| ការប្រាក់បានទទួល | | 189,281,641 | 46,552,297 | 130,554,012 | 32,132,417 |
| ការប្រាក់បានបង់ | | (79,369,992) | (19,520,411) | (51,377,845) | (12,645,298) |
| ពន្ធលើប្រាក់ចំណេញបានបង់ | | (23,750,445) | (5,841,231) | (15,249,240) | (3,753,197) |
| **សាច់ប្រាក់សុទ្ធប្រើក្នុង សកម្មភាពប្រតិបត្តិការ** | | (74,809,610) | (18,398,821) | (133,561,168) | (32,872,549) |

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល (ត)
## សម្រាប់ការិយបរិច្ឆេទ 6 ខែ ដែលបានបញ្ចប់ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019

| | កំណត់សំគាល់ | សម្រាប់ការិយបរិច្ឆេទ 6 ខែ ដែលបញ្ចប់ ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019 | | ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2018 (មិនបានត្រួតពិនិត្យ) | |
|---|---|---|---|---|---|
| | | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សំគាល់ 4) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សំគាល់ 4) |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ប្រាក់តម្កល់ធានាលើដើមទុន | | (2,084,660) | (512,705) | (4,831,590) | (1,189,168) |
| ការទិញទ្រព្យ និងបរិក្ខារ | | (4,237,975) | (1,042,296) | (957,248) | (235,601) |
| ការទិញទ្រព្យសកម្មអរូបី | | (238,576) | (58,676) | (210,052) | (51,699) |
| សាច់ប្រាក់ទទួលបានពីការលក់ទ្រព្យ និងបរិក្ខារ | | 12,719 | 3,128 | 120,616 | 29,686 |
| **សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ** | | (6,548,492) | (1,610,549) | (5,878,274) | (1,446,782) |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | | 319,829,618 | 78,659,522 | 370,052,424 | 91,078,618 |
| ការទូទាត់សងប្រាក់កម្ចី | | (157,542,176) | (38,746,231) | (167,672,645) | (41,268,187) |
| សាច់ប្រាក់ពីការលក់មូលបត្របំណុល | | 80,411,797 | 19,776,635 | - | - |
| សាច់ប្រាក់ទទួលបានពីទុនបន្ថែម | | 21,640,400 | 5,322,282 | - | - |
| **សាច់ប្រាក់សុទ្ធទទួលបានពី សកម្មភាពហិរញ្ញប្បទាន** | | 264,339,639 | 65,012,208 | 202,379,779 | 49,810,431 |
| **ការកើនឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | 182,981,537 | 45,002,838 | 62,940,337 | 15,491,100 |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី 1 ខែ មករា | | 369,537,050 | 91,970,395 | 126,552,514 | 31,348,158 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (1,376,049) | - | (200,605) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាចុងការិយបរិច្ឆេទ** | 21 | 552,518,587 | 135,597,184 | 189,492,851 | 46,638,653 |

**ប្រតិបត្តិការមិនមែនជាសាច់ប្រាក់សំខាន់ៗ៖**

នៅក្នុងការិយបរិច្ឆេទ ក្រុមហ៊ុន មានប្រតិបត្តិការមិនមែនជាសាច់ប្រាក់សំខាន់ៗ ដូចខាងក្រោម៖

| | ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019 | | ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 (មិនបានត្រួតពិនិត្យ) | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សំគាល់ 4) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សំគាល់ 4) |
| ការផ្ទេរពីដើមទុនបន្ថែមទៅជាដើមទុន | 20,846,600 | 5,127,054 | - | - |
| បង្វិលពីប្រាក់ចំណេញរក្សាទុកទៅជាដើមទុន | - | - | 48,315,900 | 12,025,000 |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅជាដើមទុន | - | - | 103,246,706 | 25,696,000 |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ ។

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## សម្រាប់ការិយបរិច្ឆេទ 6 ខែ ដែលបានបញ្ចប់ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019

## 1. អំពីក្រុមហ៊ុន

**អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី** (ត្រូវបានស្គាល់ពីមុនថាជាធនាគារភូមិ) ហៅកាត់ថា ("ក្រុមហ៊ុន") ជាក្រុមហ៊ុន ដែលមានអាជ្ញាប័ណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពីធនាគារជាតិ នៃ កម្ពុជាថ្ងៃទី 23 ខែ ឧសភា ឆ្នាំ 2002 និងធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី 28 ខែ កញ្ញា ឆ្នាំ 2015 ហើយបានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្មជាក្រុមហ៊ុនសាធារណជនទទួលខុសត្រូវមានកម្រិត ក្រោមបញ្ជីពាណិជ្ជកម្មលេខ Co. 1413 E/2002 ហើយបានប្តូរលេខចុះបញ្ជីទៅលេខ 00012829 ។ ក្រោយពីមានការផ្លាស់ប្តូររចនាសម្ព័ន្ធភាគហ៊ុននៅក្នុងខែកញ្ញាឆ្នាំ 2014 ក្រុមហ៊ុនបានក្លាយជាបុត្រសម្ព័ន្ធ របស់ក្រុមហ៊ុន LOLC Micro Investments Ltd ដែលបានចុះបញ្ជីនៅប្រទេសស្រីលង្កា ។ ក្រុមហ៊ុនមេធំបំផុត គឺក្រុមហ៊ុន Lanka ORIX Leasing Company PLC ដែលបានចុះបញ្ជីនៅប្រទេសស្រីលង្កា និងបានចុះបញ្ជីនៅផ្សារហ៊ុន Colombo ។

នៅថ្ងៃទី 16 ខែ កញ្ញា ឆ្នាំ 2017 LOLC Micro investments Ltd. និង DWM Investment Asia Ltd បានផ្ទេរ/លក់ភាគហ៊ុនទាំងអស់ 96.97% ទៅ LOLC Private Limited ។ ការផ្ទេរនេះ ត្រូវបានអនុម័តដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី 28 ខែ វិច្ឆិកា ឆ្នាំ 2017 ។ បន្ថែមទៀត ភាគហ៊ុនត្រូវបានអនុម័តក្នុងការដូរភាពជាម្ចាស់ដោយធនាគារជាតិ នៃ កម្ពុជាថ្ងៃទី 14 ខែ មីនា ឆ្នាំ 2018 និងទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី 25 ខែ មិថុនា ឆ្នាំ 2018 ។

នៅថ្ងៃទី 11 ខែ កញ្ញា ឆ្នាំ 2015 ក្រុមហ៊ុនទទួលបានអាជ្ញាប័ណ្ណសម្រាប់ការទទួលប្រាក់បញ្ញើពីសាធារណជន ដើម្បីធ្វើអាជីវកម្មទទួលប្រាក់បញ្ញើ ពីធនាគារជាតិ នៃ កម្ពុជា ។

ក្រុមហ៊ុនមាន 79 ការិយាល័យ (សាខាចំនួន 78 ការិយាល័យ និងទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ) ។ ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុនមានទីតាំងស្ថិតនៅអាគារលេខ 666B ផ្លូវលេខ 271 សង្កាត់ បឹងទំពុនទី 2 ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

នាថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019 ក្រុមហ៊ុនមានបុគ្គលិកចំនួន 2,327 នាក់ (31 ខែ ធ្នូ ឆ្នាំ 2018: 2,065 នាក់) ។

## អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

### កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
### សម្រាប់ការិយបរិច្ឆេទ 6 ខែ ដែលបានបញ្ចប់ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019

### 2. មូលដ្ឋាននៃការរៀបចំ

#### (ក) របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមគោលនយោបាយគណនេយ្យដែលទទួលស្គាល់ និងប្រើប្រាស់ជាទូទៅ នៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល ។ សម្រង់កំណត់ពន្យល់ខ្លះៗ ត្រូវបានបញ្ចូលដើម្បីពន្យល់អំពីព្រឹត្តិការណ៍ និងប្រតិបត្តិការដែលមានសារៈសំខាន់ ដើម្បីស្វែងយល់អំពីការផ្លាស់ប្តូរស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនចាប់តាំងពីរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំចុងក្រោយ សម្រាប់ការិយបរិច្ឆេទនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 និងដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 ។

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល របស់ក្រុមហ៊ុន ត្រូវបានអនុម័ត និងផ្តល់សិទ្ធិផ្សាយដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី 14 ខែ សីហា ឆ្នាំ 2019 ។

#### (ខ) មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល របស់ក្រុមហ៊ុនត្រូវបានរៀបចំឡើងទៅតាមមូលដ្ឋានតម្លៃដើម ។

#### (គ) រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ

ក្រុមហ៊ុនធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួនផ្អែកលើរូបិយប័ណ្ណចំនួនបី គឺប្រាក់រៀល ប្រាក់ដុល្លារអាមេរិក និងប្រាក់បាតថៃ ។ អ្នកគ្រប់គ្រងបានកំណត់ប្រាក់រៀល ជារូបិយប័ណ្ណមុខងារ និងជារូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ ព្រោះវាឆ្លុះបញ្ចាំងពីភាពចាំបាច់នៃសេដ្ឋកិច្ច ប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន ។

សកម្មភាពប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗទៀតក្រៅពីប្រាក់រៀល ត្រូវបានប្តូរទៅជាប្រាក់រៀល ដោយប្រើអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ ។ សមតុល្យនៃទ្រព្យសកម្មរូបិយវត្ថុ និងបំណុលរូបិយវត្ថុនាកាលបរិច្ឆេទរាយការណ៍ ដែលជារូបិយប័ណ្ណក្រៅពីប្រាក់រៀល ក៏ត្រូវបានប្តូរទៅជាប្រាក់រៀលដោយប្រើអត្រានាកាលបរិច្ឆេទនោះ ។ ភាពលម្អៀងពីការប្តូររូបិយប័ណ្ណដែលកើតមកពីការប្តូរនោះ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលសង្ខេបចន្លោះពេល ។

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត) សម្រាប់ការិយបរិច្ឆេទ 6 ខែ ដែលបានបញ្ចប់ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019

### 2. មូលដ្ឋាននៃការរៀបចំ (ត)

### (ឃ) ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល តម្រូវឲ្យធ្វើការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មត់តាមគណនេយ្យឲ្យបានច្បាស់ដែល មានផលប៉ះពាល់ដល់ចំនួននៃទ្រព្យសកម្មបំណុល និងការង្ហាញនូវទ្រព្យសកម្ម និងបំណុលយថាភាព នាការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល និងរបាយការណ៍ចំណូល និងចំណាយដែលបានរាយការណ៍ក្នុងកំឡុងពេលរាយការណ៍ ។ ការប៉ាន់ស្មាននេះតម្រូវឲ្យអ្នកគ្រប់គ្រង ប្រើប្រាស់ការវិនិច្ឆ័យ ដោយអនុលោមតាមគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុន ។ ថ្វីបើការប៉ាន់ស្មាន និងការសន្មត់របស់អ្នកគ្រប់គ្រងផ្អែកលើការមើលឃើញពីព្រឹត្តិការណ៍ និងសកម្មភាពបច្ចុប្បន្ន លទ្ធផលជាក់ស្តែងអាចខុសពីការ ប៉ាន់ស្មានទាំងនោះ ។

ផ្នែកដែលតម្រូវឲ្យមានកម្រិតក្នុងការប៉ាន់ស្មានខ្ពស់ និងស្មុគស្មាញ ឬផ្នែកដែលការសន្មត់ និងការប៉ាន់ស្មានមានផលប៉ះពាល់ជាសារវន្តដល់របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលមានដូចខាងក្រោម៖

*(i) ការខាតបង់លើការថយចុះតម្លៃនៃឥណទានផ្តល់ឲ្យអតិថិជន និងប្រាក់សមតុល្យនៅធនាគារនានា*

ក្រុមហ៊ុន បានអនុវត្តការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន ដែលតម្រូវដោយប្រកាស របស់ធនាគារជាតិនៃកម្ពុជា លេខ ធ7-017-344 ប្រ.ក ចុះថ្ងៃទី 1 ខែ ធ្នូ ឆ្នាំ 2017 និងសារាចរណែនាំលេខ ធ7-018-001 ស.រ.ច.ណ ចុះថ្ងៃទី 16 ខែ កុម្ភៈ ឆ្នាំ 2018 ស្តីពី "ចំណាត់ថ្នាក់ ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន" សម្រាប់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ។ ឥណទាន ផលិតផលហិរញ្ញវត្ថុផ្សេងៗ និងកិច្ចសន្យាហិរញ្ញវត្ថុក្រៅតារាងតុល្យការ ត្រូវបានបែងចែកជាប្រាំថ្នាក់ ហើយត្រូវកត់ត្រាសំវិធានធនអាស្រ័យទៅតាមចំណាត់ថ្នាក់របស់វា ដោយមិនគិតដល់ទ្រព្យសកម្មដែលត្រូវបានដាក់ជាវត្ថុបញ្ចាំ (លើកលែងតែសាច់ប្រាក់) ។ ក្រុមប្រឹក្សាភិបាលជឿជាក់ថាអាយុកាលឥណទាន (តាមចំនួនថ្ងៃផុតកំណត់) ដែលជាមូលដ្ឋានកំណត់ចំណាត់ថ្នាក់ឥណទាន មានភាពសមស្របដើម្បីកំណត់ភាពគ្រប់គ្រាន់នៃការខាតបង់បណ្តាលមកពីការថយចុះតម្លៃនៃឥណទាន ដើម្បីឱ្យស្របតាមប្រកាសនេះ ។

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ការិយបរិច្ឆេទ 6 ខែ ដែលបានបញ្ចប់ថ្ងៃទី 30 ខែ មិថុនា ឆ្នាំ 2019

### 2. មូលដ្ឋាននៃការរៀបចំ (ត)

### (ឃ) ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

*(i) ការខាតបង់លើការថយចុះតម្លៃនៃឥណទានផ្តល់ឲ្យអតិថិជន និងប្រាក់សមតុល្យនៅធនាគារនានា (ត)*

សំវិធានធនលើឥណទាន ត្រូវបានបង្ហាញជាការកាត់បន្ថយពីឥណទាន ។ តារាងខាងក្រោមបង្ហាញពីចំណាត់ថ្នាក់ និងតម្រូវការសំវិធានធនតាមបទប្បញ្ញត្តិ៖

| ការចាត់ថ្នាក់ | ចំនួនថ្ងៃហួសកំណត់ | សំវិធានធន |
|---|---|---|
| រយៈពេលខ្លី | | |
| ធម្មតា | តិចជាង 15 ថ្ងៃ | 1% |
| ឃ្លាំមើល | 15 ថ្ងៃ – 30 ថ្ងៃ | 3% |
| ក្រោមស្តង់ដា | 31 ថ្ងៃ – 60 ថ្ងៃ | 20% |
| ជាប់សង្ស័យ | 61 ថ្ងៃ – 90 ថ្ងៃ | 50% |
| ខាតបង់ | 91 ថ្ងៃ ឬលើស | 100% |
| រយៈពេលវែង | | |
| ធម្មតា | តិចជាង 30 ថ្ងៃ | 1% |
| ឃ្លាំមើល | 30 ថ្ងៃ – 89 ថ្ងៃ | 3% |
| ក្រោមស្តង់ដា | 90 ថ្ងៃ – 179 ថ្ងៃ | 20% |
| ជាប់សង្ស័យ | 180 ថ្ងៃ – 359 ថ្ងៃ | 50% |
| ខាតបង់ | 360 ថ្ងៃ ឬលើស | 100% |

*(ii) ពន្ធ*

